**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២៤/០២/២០១០ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១០

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប**

**កម្មវត្ថុ :** សំណើសុំចាត់វិធានការឱ្យរាជរដ្ឋាភិបាលកម្ពុជា ផ្អាកការបោះបង្គោលលក្សតាមដងព្រំដែនកម្ពុជា-វៀតណាម ដើម្បីធានានូវការគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**យោង :** លិខិតលេខ ០០៣.១០ រ.ស.គ.ស.រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤ រូប ។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំ នាថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើរបស់ឯកឧត្តម លោកជំទាវ រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សំណើសុំចាត់វិធានការឱ្យរាជរដ្ឋាភិបាលកម្ពុជា ផ្អាកការបោះបង្គោលលក្សតាមដងព្រំដែនកម្ពុជា-វៀតណាម ពុំចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**